# សេចក្តីណែនាំ

## ស្តីពី

## របៀបប្រើប្រាស់កម្មវិធីរៀនតាមរយៈឌីជីថល

ថ្នាក់រៀនបែបឌីជីថលជាមួយមជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព (NCHP) គឺជាវិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រផ្សេងៗជាច្រើនទៀតដែលអនុញ្ញាតិឱ្យអ្នកចូលរៀនពីប្រធានបទសុខភាព ឬប្រធានបទពាក់ព័ន្ធកូវីដ១៩។ ក្រោមកិច្ចសហការ និងជំនួយបច្ចេកទេសពីយូនីសេហ្វ (UNICEF) វេទិកាឌីជីថលចំនួនពីរត្រូវបានរៀបចំឡើងដើម្បីអនុញ្ញាតិឱ្យអ្នក និងសហគមន៍របស់អ្នក អាចសិក្សាលើប្រធានសុខភាពណាមួយពីចម្ងាយទោះបីជាមាន ឬគ្មានសេវាអ៊ីនធើណេតក្នុងតំបន់ដែលលោកអ្នករស់នៅក៏ដោយ ។ វេទិកាឌីជីថលទាំងនោះរួមមាន ម៉ូដល (Moodle) និងតេលេក្រាមឆាតប៊ិត (Telegram Chatbot) ។ សូមអានជំពូកខាងក្រោមនេះដើម្បីស្វែងយល់លំអិតអំពីរបៀបចូលរៀនតាមម៉ូដល និងតេលេក្រាមឆាតប៊ិត ។

## ជំពូកទី១៖ ចូលរៀនតាមប្រព័ន្ធម៉ូដលក្នុងទូរស័ព្ទ

### ១.១ ទិដ្ឋភាពទូទៅនៃម៉ូដល

✓ អាសយដ្ឋានម៉ូដល៖ https://cambodia.moodlecloud.com/

✓ តម្រូការចាំបាច់ដែលអាចប្រើប្រាស់ម៉ូដលបាន៖

1. ស្គាល់អាសយដ្ឋានម៉ូដល
2. មានទូរស័ព្ទចុចលើអេក្រង់ (ទូរស័ព្ទឆ្លាតវៃ) ឬកុំព្យូទ័រ
3. មានអាសយដ្ឋានអ៊ីមែលផ្ទាល់ខ្លួន

✓ ចំនុចគួរពិចារណា៖

| ចំនុចខ្លាំងរបស់ម៉ូដល | ចំនុចគួរដឹង |
|---|---|
| 1. រៀនតាមរយៈគេហទំព័រ និងកម្មវិធីក្នុងកុំព្យូទ័រ ទូរស័ព្ទដៃ និងតាប្លែត ។<br>2. អាចប្រើប្រាស់អ៊ីមែលក្លែងក្លាយដើម្បីចុះឈ្មោះចូលរៀនបានសម្រាប់អ្នកដែលគ្មានអ៊ីមែល ។<br>3. អាចបន្តរៀនបានទោះមានឬគ្មានសេវាអ៊ីនធើណេតក៏ដោយ ។ | 1. មិនលើកទឹកចិត្តឱ្យប្រើម៉ូដលទេ បើអ្នកគ្មានអាសយដ្ឋានអ៊ីមែលផ្ទាល់ខ្លួន ។<br>2. អ្នកត្រូវទាញយកមាតិការមេរៀនកន្លែងដែលមានសេវាអ៊ីនធើណេត ទុករៀននៅទីតាំងដែលគ្មានអ៊ីនធើណេត ។<br>3. ក្រោយរៀនចប់នៅទីតាំងដែលគ្មានអ៊ីនធើណេត អ្នកត្រូវបញ្ជូនលទ្ធផលរៀនរបស់អ្នកតាមរយៈអ៊ីនធើណេត ។ |

*ចំណាំ៖ រូបភាពខាងក្រោមដកស្រង់ចេញពីកម្មវិធីទូរស័ព្ទប្រព័ន្ធអេនឌ្រ័យប៉ុណ្ណោះ!*

## ១.២ របៀបទាញយកកម្មវិធីមូ៉ដលចូលទូរស័ព្ទ




## ១.៣ របៀបបង្កើត និងស្នើសុំឈ្មោះប្រើប្រាស់ក្នុងមូ៉ដល



## ១.៤ របៀបចូលប្រើប្រាស់ម៉ូដល




## ១.៥ របៀបចូលរៀនប្រធានបទ និងកត់ត្រាលទ្ធផលរៀន



## ១.៦ ពេលគ្មានអ៊ីនធើណេត

### ១.៦.១ របៀបទាញមេរៀនទុករៀននៅក្នុងទូរស័ព្ទដៃពេលគ្មានប្រព័ន្ធអ៊ីនធើណេត

*ចំណាំ៖ អ្នកត្រូវមានសេវាអ៊ីនធើណេតដើម្បីទាញយកមេរៀនទាំងស្រុង ឬជំពូក ឬផ្នែកណាមួយនៃមេរៀនដែល អ្នកចង់យកទៅរៀននៅកន្លែងគ្មានអ៊ីនធើណេត ។*




### ១.៦.២ របៀបបញ្ជូនលទ្ធផលដែលអ្នកបានរៀនពេលគ្មានអ៊ិនធើណេតទៅប្រព័ន្ធអនឡាញ

*ចំណាំ៖ អ្នកត្រូវមានសេវាអ៊ីនធើណេតដើម្បីដាក់បញ្ចូលលទ្ធផលរៀនដែលអ្នកបានរៀនពេលគ្មានអ៊ិនធើណេត ។*



## ១.៧ ធ្វើតេស្តចំណេះដឹងមុន និងក្រោយសិក្សា




**(3)** ជ្រើសរើសចម្លើយដែលអ្នកគិតថាត្រឹមត្រូវ ចាប់ពីសំនួរតំបូងរហូតដល់សំនួរចុងក្រោយ ។

**(4)** ចុងក្រោយចុចលើប្រអប់ [SUBMIT] ដើម្បីរក្សាទុកចម្លើយរបស់អ្នកជាការស្រេច ។

*ចំណាំ៖ តេស្តមុនចូលរៀនមិនបង្ហាញចម្លើយខុសឬត្រូវទេ ។ តែតេស្តក្រោយរៀនចប់ ប្រសិនបើអ្នកឆ្លើយខុស វានឹងបង្ហាញចម្លើយដែលត្រឹមត្រូវតាមសំណួរនីមួយៗ ។*

## ជំពូកទី២៖ ចូលរៀនតាមរយៈតេលេក្រាមឆាតប៊ត

## ២.១ ទិដ្ឋភាពទូទៅនៃតេលេក្រាម

- ✓ អាសយដ្ឋានតេលេក្រាម (Telegram)៖ http://t.me/Cambodia_RHWT_Registry_bot
- ✓ តម្រូវការចាំបាច់ដែលអាចប្រើប្រាស់៖
  1. ស្គាល់អាសយដ្ឋានតេលេក្រាម
  2. មានទូរស័ព្ទចុចលើអេក្រង់ (ទូរស័ព្ទឆ្លាតវៃ) ឬកុំព្យូទ័រ
  3. មានកម្មវិធីតេលេក្រាមក្នុងទូរស័ព្ទ

✓ ចំនុចគួរពិចារណា៖

| ចំនុចខ្លាំងរបស់ម៉ូដល | ចំនុចគួរដឹង |
|---|---|
| 1. ងាយស្រួលរៀនសម្រាប់អ្នកដែលទម្លាប់ប្រើប្រាស់តេលេក្រាមក្នុងការងារប្រចាំថ្ងៃ<br>2. មិនត្រូវការតំឡើងកម្មវិធីផ្សេងៗក្នុងទូរស័ព្ទដៃដើម្បីចូលរៀន<br>3. មិនត្រូវការអាសយដ្ឋានអ៊ីមែលផ្ទាល់ខ្លួន<br>4. មិនត្រូវការចុះឈ្មោះស្នើសុំឈ្មោះប្រើប្រាស់ និងលេខកូដសម្ងាត់ | 1. មិនអាចប្រើប្រាស់បានពេលគ្មានអ៊ីនធើណេត<br>2. ពិបាកត្រឡប់ចុះឡើងពីមាតិកាមេរៀនមួយទៅមួយទៀត<br>3. មិនអាចស្វែងរកប្រវត្តិរៀនចាស់ៗបាន ប្រសិនបើមាតិការៀនត្រូវបានលុបចេញពីក្នុងទូរស័ព្ទ |

## ២.២ របៀបចូលរៀនតាមតេលេក្រាម

ការចូលរៀនតាមតេលេក្រាមមានភាពងាយស្រួលណាស់ អ្នកគ្រាន់តែចុចលើ http://t.me/Cambodia_RHWT_Registry_bot ដែលជាអាសយដ្ឋានតេលេក្រាម រួចចុចចាប់ផ្តើមចូលរៀនជាការស្រេច ។

ដំណើរការរៀនក្នុងតេលេក្រាមរួមមាន៖

ចុះឈ្មោះ → ធ្វើតេស្តមុនរៀន → អាន និងស្តាប់ពីមាតិកានីមួយៗ → ធ្វើតេស្តក្រោយរៀន

